# <u>បញ្ហាអាឡែរស៊ីអាហារនៅសាលា</u>

ប្រសិនបើកូនរបស់អ្នកមានបញ្ហាអាឡែរស៊ីអាហារដែលកំពុងគម្រាមកំហែងដល់អាយុជីវិត វាជារឿងដ៏សំខាន់ដែលអ្នកធ្វើការជាមួយគិលានុបដ្ឋាយិការប្រចាំសាលារបស់អ្នកដើម្បីបង្កើតជាផែនការថែទាំសុខភាពតម្រូវតាមរៀងៗខ្លួនដើម្បីធានាបាននូវបរិស្ថានសិក្សាប្រកបដោយសុវត្ថិភាព។ គិលានុបដ្ឋាយិការប្រចាំសាលានឹងត្រូវការវេជ្ជបញ្ជាពីគ្រូពេទ្យនូវឧបករណ៍ចាក់ថ្នាំអេពីណេហ្វ្រីនដោយស្វ័យប្រវត្តិ ត្រូវការការយល់ព្រមរបស់មាតាបិតាដើម្បីអោយថ្នាំបើចាំបាច់ និងផែនការសកម្មភាពលើបញ្ហាអាឡែរស៊ី។ គិលានុបដ្ឋាយិការប្រចាំសាលានឹងអប់រំណែនាំបុគ្គលិកសាលាអោយធ្វើការជាមួយកូនរបស់អ្នក និងបង្កើតជាផែនការដែលផ្តោតលើការការពារប្រតិកម្មអាឡែរស៊ីកំឡុងពេលថ្ងៃសិក្សា។



